# មាតិកា

## I.ខុទ្ទកាល័យព្រះមហាក្សត្រ

### ១.ព្រះរាជក្រម

២៩-៦-២០០៧ -ព្រះរាជក្រម នស/រកម/០៦០៧/០១៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅព្រះរាជាណាចក្រកម្ពុជា ៥០៨១

### ២.ព្រះរាជក្រឹត្យ

០៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៧១ ស្តីពីការតែងតាំងឯកឧត្តម **មាន ចាន់យ៉ាដា** ជាជំនួយការលោកជំទាវ **ឃួន សុដារី** ប្រធានគណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា មានឋានៈស្មើ អគ្គនាយក ៥០៩៨

០៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៧៣ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **ម៉ែន ដារេត** នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ៥០៩៩

០៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៧៤ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **ឌី ថេយឿត** នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ៥១០០

០៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៧៥ ស្តីពីការប្រគល់ឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី នាយអាវុធហត្ថ ជូនលោក **ខូច សម្បត្តិ** ៥១០១

០៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៧៦ ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ៥១០២

០៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៧៧ ស្តីពីការតែងតាំង លោកស្រី **ចា ចន្នី** ជា ឧកញ៉ា ៥១០៤

០៧-៧-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៧០៧/២៧៨ ស្តីពីការតែងតាំង លោកជំទាវ **ម៉ែន នារីសោភ័គ** ជានាយិការងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៥១០៥

# II_ រាជរដ្ឋាភិបាល

## ១_ អនុក្រឹត្យ


| | | |
|---|---|---|
| ០៥-៧-២០០៧ | -អនុក្រឹត្យលេខ ៦៨ អនក្រ.បក ស្តីពីការធ្វើអនុបយោគទីតាំងកោះមួយចំនួន ក្នុងភូមិសាស្ត្រ ក្រុងព្រះសីហនុ និងខេត្តកំពត ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ | ៥១០៦ |
| ១០-៧-២០០៧ | -អនុក្រឹត្យលេខ ៦៩ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា | ៥១០៨ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥០៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៥១១០ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥០៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១១៨ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១១៩ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៥១២០ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១២១ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១២២ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី | ៥១២៤ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ | ៥១២៥ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ | ៥១២៦ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៥១២៧ |
| ០៥ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១៨ អនក្រ.តត ស្តីពីការបន្ថែមសមាសភាពនៃក្រុមការងាររបស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិជ្ជាការនិងវិសហមជ្ឈការ (គ.ជ.វ.វ.) | ៥១២៨ |
| ០៦ -៧-២០០៧ | -អនុក្រឹត្យលេខ ៥១៩ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន | ៥១៣០ |
| ០៦ -៧-២០០៧ | -អនុក្រឹត្យលេខ ៥២០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១៣២ |
| ០៦ -៧-២០០៧ | -អនុក្រឹត្យលេខ ៥២១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៥១៣៣ |
| ០៦ -៧-២០០៧ | -អនុក្រឹត្យលេខ ៥២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ៥១៣៥ |


## ២_ សេចក្តីសំរេច


| | | |
|---|---|---|
| ០៤ -៧-២០០៧ | -សេចក្តីសំរេចលេខ ៣២ សសរ ស្តីពីការចាត់តាំងមន្ត្រីរាជការ | ៥១៣៧ |
| ០៨ -៧-២០០៧ | -សេចក្តីសំរេចលេខ ៣៣ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល | ៥១៣៨ |

## III. ការិយាល័យក្រសួង

### ១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

#### ប្រកាស

១២-៦-២០០៧ -ប្រកាសលេខ ៤៦៥ សហវ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជា ឆ្នាំ ២០០៧ *( ត មកពីរាជកិច្ច លេខ ៤៩.៥០.៥១ )* ៥១៣៥

### ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូស៊ិន ផៅវ័រ ទិច** ៥១៨០

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.អិម.ធី** ៥១៨២

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៣២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជាង ជុង អ៊ិនធើណេសិនណល ត្រេឌីង** ៥១៨៤

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៣៣ពណ.នតក ស្តីពីការអនុញ្ញាតជាគោលការណ៍ អោយ បង្កើតការិយាល័យតំណាងពាណិជកម្មនៃក្រុមហ៊ុន **អេគ្រីខលឆឺរ៉ល ឌីវេឡុបមេន អ៊ិនធើណេសិនណល (ខេមបូឌា)** ប្រចាំរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនៅប្រទេសអូស្ត្រាលី ៥១៨៦

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន និង សាខាក្រុមហ៊ុន **អ៊ិនធើណេសិនណល អ៊ិនវ៉ាយរ៉ុនម៉ិនថល មេនេចមេន** ៥១៨៧

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៣៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឃ្លោលជេន មៀរ ខូ អិលធីឌី** ៥១៨៨

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាយអូ ធ័ន អ៊ីន** ៥១៩០

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី ធី ស៊ី ឡូជីស្ទីក** ៥១៩២

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៤៥ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌ្លីកណិត ខូ អិលធីឌី** ៥១៩៤

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៥១ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អានគ័រ ឌីវេឡុបមេន** ៥១៩៦

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៥២ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈរាឃ្លាណស្វី** ៥១៩៨

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៥៣ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ អេស៊ាន ធ័រ**
**ខូ.អិលធីឌី** ៥២០០

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៥៤ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្វ័រ ឌីវេឡុបមេន** ៥២០២

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៥៥ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុនដើម និងសាខាក្រុមហ៊ុន
**សុឡិច ម៉ាឃីន** ៥២០៤

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៥៨ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច អេស ភី**
**ខមម៉ើសល អេស៊ា** ៥២០៥

១៤-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៦២ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ុយ សាំងអេង** ៥២០៧

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៦៤ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេនស្ការ ភីធីអុី**
**អិលធីឌី** ៥២០៩

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៦៥ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចឹង យាន គ្រុប**
**(ខេមបូឌា)** ៥២១១

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៦៦ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស៊ា ផេស៊ីហ្វិក**
**ហ្វើទីឡាយហ្ស៊ើ (ខេមបូឌា) លីមីធីត** ៥២១៣

១៥-០២-២០០៧ -លិខិតបញ្ជាក់លេខ ០៧៦៧ ពណ.នគក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សែនឌីវែល** ៥២១៥

# ព្រះរាជក្រម

នស/រកម/០៦០៧/០១៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និង ឧតុនិយម
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# ការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា



# ជំពូកទី ១

# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅធានាឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ ។

ច្បាប់នេះកំណត់ :

-សិទ្ធិ និងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹក

-គោលការណ៍គ្រឹះសំខាន់ៗ សម្រាប់ការគ្រប់គ្រងធនធានទឹក

-ការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹក ក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព ។

**មាត្រា ២.-**

ក្នុងច្បាប់នេះ ពាក្យបច្ចេកទេសមួយចំនួនមានន័យថា :

-ទឹក គឺទឹកលើដី ទឹកក្រោមដី និងទឹកក្នុងអាកាស ។

-ធនធានទឹក គឺសមុទ្រ ទន្លេ ស្ទឹង ព្រែក ជ្រោះ ជ្រលងជងអូរ បឹងបួ ត្រពាំង ថ្លុក អាងទឹក ។

-ទឹកក្រោមដី គឺទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូច ធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ។

-ល្អាងទឹកក្រោមដី គឺទឹកក្រោមដីដែលស្ថិតនៅជាអចិន្ត្រៃយ៍ក្នុងល្អាងធម្មជាតិក្រោមដី ។

-អាងទន្លេ គឺតំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់នីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី ។

-អាងទន្លេរង គឺផ្នែកមួយនៃអាងទន្លេ ។

-ទន្លេអន្តរជាតិ គឺទន្លេដែលមានភូមិសាស្ត្រពាក់ព័ន្ធដល់ទឹកដីប្រទេសចាប់ពី

-ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺចំណែកដីដែលធម្មតាលិចដោយទឹកនៅក្នុងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក ដោយរាប់បញ្ចូលទាំងដី ថ្ម ឬ អង្គធាតុដទៃទៀតដែលជាប់នៅនឹងច្រាំងនោះ ដោយមិនរាប់បញ្ចូលនូវដី ថ្ម ឬ អង្គ-ធាតុដទៃទៀតដែលនៅឆ្ងាយពីច្រាំង និងលិចទឹកម្តងម្កាលនោះទេ ។

-ឆ្នេរ សមុទ្រ ទន្លេ ស្ទឹងគឺចំណែកដី ឬ ខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល ។

-បាតទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹក គឺផ្នែកមួយនៃដីដែលកំណត់ដោយច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ បឹងបួ និងអាងទឹកដែលគ្របដណ្តប់ដោយទឹក ។

-តម្រូវការសាធារណៈ គឺការផ្គត់ផ្គង់ទឹកទៅតាមទីក្រុង និងជនបទ ការផលិតស្បៀង ការផលិតថាមពលវារីអគ្គិសនី ការបំរើវិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យនាវាចរ និងការរក្សាឱ្យមានធារទឹកអប្បបរមា ដើម្បីថែរក្សាបរិស្ថាន ជីវិតមនុស្ស ជីវិតមច្ឆា-ជាតិ និងរុក្ខជាតិនានា ។

-ការងារទឹក គឺសំណង់ទំនប់ធំ តូច ទំនប់បង្វៀរ ទំនប់បញ្ជាល់ទឹក ទំនប់ការពារទឹកជំនន់ ប្រឡាយដោះទឹកធំតូច ប្រព័ន្ធស្រោចស្រព អាងទឹកធំ តូច ប្រឡាយនាំទឹក អណ្តូងទឹកគ្រប់ប្រភេទ ទំនប់វារីអគ្គិសនី និងសំណង់ដទៃទៀត ដែលបានសាងសង់ក្នុងគោលបំណងបង្វែរទឹក រក្សាទឹកទុក នាំទឹកយកទឹកប្រើប្រាស់ អភិរក្ស ការពារធនធានទឹក ដោះទឹកចេញពីតំបន់ដីលិចទឹក ការពារកាត់បន្ថយនូវឥទ្ធិពលទឹកជំនន់ និងសង្គ្រោះបន្ទាន់ផ្សេងៗទៀតដែលពាក់ព័ន្ធនឹងទឹក ។

-អាជ្ញាប័ណ្ណទឹក គឺប័ណ្ណដែលផ្តល់សិទ្ធិប្រើប្រាស់ទឹក និងធនធានទឹកឱ្យដល់បុគ្គលគ្រប់រូបដើម្បីធ្វើអាជីវកម្ម និងអភិវឌ្ឍ ។

-បុគ្គល គឺរូបវន្តបុគ្គល ឬ នីតិបុគ្គលទោះក្នុងន័យជាឯកជន ឬ សាធារណៈក៏ដោយ ។

**មាត្រា ៣.-**

ទឹក និងធនធានទឹក ជាសម្បត្តិរបស់រដ្ឋ ។

**មាត្រា ៤.-**

ទឹក និងធនធានទឹកត្រូវបានគ្រប់គ្រង និងអភិវឌ្ឍដោយផ្អែកទៅលើវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះ ។

វិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះនេះ នឹងពិចារណាទៅលើ :

-គ្រប់ទិដ្ឋភាពទាំងអស់នៃធនធានទឹក

-ទំនាក់ទំនងរវាងធនធានទឹក និងទិដ្ឋភាពដទៃទៀតនៃបរិស្ថានធម្មជាតិ

-តម្រូវការប្រើប្រាស់ទឹកសំរាប់មនុស្ស បរិស្ថាន និងវិស័យផ្សេងទៀត ដើម្បីឱ្យមាននិរន្តរភាព និងប្រសិទ្ធភាព ។

ការអនុវត្តនីវិធីសាស្ត្រគ្រប់គ្រងធនធានទឹកចំរុះ ត្រូវធ្វើក្នុងពេលតែមួយ និងក្នុងក្របខ័ណ្ឌសហប្រតិបត្តិការរវាងរាល់ស្ថាប័នពាក់ព័ន្ធ ។

**មាត្រា ៥.-**

ក្រសួងធនធានទឹក និងឧតុនិយមមានភារកិច្ចគ្រប់គ្រង ដឹកនាំ និងត្រួតពិនិត្យ ក្នុងការអនុវត្តនីច្បាប់នេះ ។ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយនឹងក្រសួងពាក់ព័ន្ធនានា ។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចនឹងបង្កើតគណៈកម្មការចំរុះចំពោះមុខដើម្បីដោះស្រាយ និងសំរបសំរួលការងាររវាងបណ្តាក្រសួងពាក់ពន្ធ័ ។

**មាត្រា ៦.-**

ក្នុងការអនុវត្តនីច្បាប់គ្រប់គ្រងធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយម ត្រូវកំណត់គោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹក ស្របតាមតម្រូវការរបស់តំបន់នីមួយៗនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងទិសដៅធានានិរន្តរភាពធនធានទឹក និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ទឹក ដើម្បីជៀសវាងមហន្តរាយ និងវិវាទផ្សេងៗ ។

ការបែងចែកតំបន់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹកត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

ការសហការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន អ្នកទទួលផលគ្រប់ប្រភេទ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ នឹងត្រូវបានជំរុញដោយរាជរដ្ឋាភិបាល

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

នៅក្នុងសកម្មភាពដែលទាក់ទងទៅនឹងការគ្រប់គ្រង ការវិនិយោគ ការធ្វើអាជីវកម្ម ការអភិរក្ស និងការអភិវឌ្ឍន៍ធនធានទឹក ។

## ជំពូកទី ២
## សារពើភ័ណ្ឌ និងផែនការគ្រប់គ្រងធនធានទឹក

**មាត្រា ៨.-**

ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចរៀបចំ និងរក្សាទុកនូវរាល់សារពើភ័ណ្ឌធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា ។ សារពើភ័ណ្ឌនេះ បង្ហាញអំពីទីតាំង បរិមាណ និងគុណភាពនៃធនធានទាំងនោះ ក្នុងរយៈពេលពេញមួយឆ្នាំទៅមួយឆ្នាំ ។

ទិន្នន័យស្តីពីបរិមាណ និងគុណភាពទឹក និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងទឹកដែលស្ថាប័ននានាប្រមូលបានត្រូវបញ្ជូនមកក្រសួងធនធានទឹក និងឧតុនិយមតាមស្តង់ដារបច្ចេកទេស ។

ព័ត៌មាន និងទិន្នន័យខាងលើនេះអាចផ្តល់ជូនបានដោយឥតគិតថ្លៃដល់គ្រប់ស្ថាប័នរាជរដ្ឋាភិបាល និងសហគមន៍នានា ក្នុងទិសដៅបំរើផលប្រយោជន៍សាធារណៈ លើកលែងតែព័ត៌មាន និងទិន្នន័យសម្ងាត់ ។

ក្រសួងធនធានទឹក និងឧតុនិយម អាចតម្រូវឱ្យមានការបង់ប្រាក់ចំពោះពាក្យសុំទាំងឡាយណា ដែលធ្វើឡើងក្នុងគោលបំណងអាជីវកម្ម ។

**មាត្រា ៩.-**

ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចរៀបចំផែនការធនធានទឹកជាតិ ។

រាល់គម្រោងការងារទឹក ត្រូវរៀបចំឡើងដោយផ្អែកលើទិន្នន័យ និងព័ត៌មានក្នុងបញ្ជីសារពើភ័ណ្ឌធនធានទឹក ស្របតាមផែនការធនធានទឹកជាតិ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ផែនការបរិស្ថានជាតិ និងបរិស្ថានតំបន់ ដើម្បីរក្សាឱ្យបាននូវតុល្យភាពទៅតាមតម្រូវការទឹកនាពេលបច្ចុប្បន្ន និងពេលអនាគត ។

**មាត្រា ១០.-**

ក្រសួងធនធានទឹក និងឧតុនិយម មានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងអាងទន្លេ អាងទន្លេរង ទឹកលើទីជំរាល ទឹកក្រោមដី និងល្អាងទឹកក្រោមដីដោយសហការជាមួយនឹងក្រសួងពាក់ព័ន្ធ ។

នីតិវិធីនៃការរៀបចំ និងការអនុវត្តន៍ផែនការនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍន៍អាងទន្លេ អាងទន្លេរង ទឹកលើទីជំរាល ទឹកក្រោមដី និងល្អាងទឹកក្រោមដី ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានទឹក

**មាត្រា ១១.-**

បុគ្គលគ្រប់រូប មានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានសម្រាប់ការហូបចុក បោកគក់ ងូត និងតម្រូវការផ្សេងទៀត រួមមានការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការស្រោចស្រពសួនច្បារ និងដំណាំ ដោយចៀសវាងមិនឱ្យមានការប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់អ្នកដទៃ ។

តម្រូវការខាងលើនេះ មិនតម្រូវឱ្យសុំអាជ្ញាប័ណ្ណទឹកឡើយ ។

**មាត្រា ១២.-**

ការបង្វែរទឹក ការយកទឹក ការប្រើប្រាស់ធនធានទឹក ក្នុងគោលបំណងកសិកម្ម ឬឧស្សាហកម្ម លើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ និងសំណង់ការងារទឹកដែលពាក់ពន្ធ័ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត ។

បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ ។

ការយកខ្សាច់ ដី ថ្ម ក្រួស ប្រេងកាត និងឧស្ម័នពីបាត ច្រាំង ឆ្នេរសមុទ្រ ឆ្នេរទន្លេ ស្ទឹង ព្រែក អូរ បឹងបួ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ។ បែបបទបច្ចេកទេសជលសាស្ត្រដែលពាក់ព័ន្ធនឹងការងារនេះនឹងមានចែងលំអិតនៅក្នុងអនុក្រឹត្យ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹងបួ ប្រឡាយ អាងទឹក និងអាងធម្មជាតិ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត ។ បែបបទនៃការសុំនេះ នឹងមានចែងនៅក្នុងអនុក្រឹត្យ ។

ការសាងសង់ស្ពានតូច ធំកាត់ទន្លេ ស្ទឹង កំពង់ផែ ឬ សំណង់អាគារតូច ធំលើច្រាំង និងឆ្នេរ តម្រូវឱ្យមានការឯកភាពផ្នែកបច្ចេកទេសជលសាស្ត្រជាមុន ពីក្រសួងធនធានទឹក និងឧតុនិយម ។

ការបង្វែរទឹកពីប្រភពដើមចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវមានការអនុញ្ញាត និងយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ដោយមានការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ ។

**មាត្រា ១៣.–**

លក្ខខណ្ឌ ទម្រង់បែបបទ និងនីតិវិធីនៃការផ្តល់ ការផ្ទេរ ការព្យួរទុក ការកំណត់រយៈពេល ការពន្យារពេល ការលុបចោលអាជ្ញាប័ណ្ណទឹក ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការកំរិតតម្លៃនៃការប្រើប្រាស់ទឹកដែលជាកម្មវត្ថុនៃអាជ្ញាប័ណ្ណទឹក នឹងមានកំណត់នៅក្នុងអនុក្រឹត្យ ។

**មាត្រា ១៤.–**

មុនពេលផ្តល់អាជ្ញាប័ណ្ណទឹកដល់បុគ្គលណាមួយ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានលើការប្រើប្រាស់ទឹក និងការសាងសង់សំណង់ការងារទឹកដែលបុគ្គលនោះស្នើឡើង ។

**មាត្រា ១៥.–**

អ្នកកាន់អាជ្ញាប័ណ្ណទឹក មានសិទ្ធិផ្ទេរទាំងស្រុង ឬ ចំណែកខ្លះទៅឱ្យអ្នកដទៃផ្សេងទៀតបាន ក្រោយពីមានការយល់ព្រមពីក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ១៦.–**

រាជរដ្ឋាភិបាល អាចធ្វើការកែប្រែអាជ្ញាប័ណ្ណទឹក ក្នុងករណីមានតម្រូវការចាំបាច់ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ។ ក្នុងករណីនេះ អ្នកកាន់អាជ្ញាប័ណ្ណទឹកអាចបានទទួលនូវសំណងសមស្រប ។

ROYAUME DU CAMBODGE · REGISTRE DU PALAIS ROYAL

**មាត្រា ១៧.-**

ក្រសួងធនធានទឹក និងឧតុនិយម អាចធ្វើការកែប្រែ ឬ លុបចោលអាជ្ញាប័ណ្ណទឹកបាន តាមសំណូមពររបស់អ្នកកាន់អាជ្ញាប័ណ្ណទឹក ។

ក្រសួងធនធានទឹក និងឧតុនិយម អាចកែប្រែ ព្យួរទុក ឬ លុបចោលបានទូវអាជ្ញាប័ណ្ណទឹក ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណទឹកបាន :

-រំលោភលើលក្ខខណ្ឌដែលមានចែងក្នុងអាជ្ញាប័ណ្ណទឹក

-រំលោភលើបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធនឹងច្បាប់នេះ

-ប្រើប្រាស់បរិមាណទឹកលើសពីការអនុញ្ញាត

-ទុកចោលមិនបានអនុវត្តការងារក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីថ្ងៃទទួលអាជ្ញាប័ណ្ណទឹក

-ផ្ទេរអាជ្ញាប័ណ្ណទឹកដោយគ្មានការយល់ព្រមពីក្រសួង

-ធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ ឬ បរិស្ថាន

-បដិសេធមិនព្រមបង់តម្លៃទឹក ដោយគ្មានមូលហេតុត្រឹមត្រូវ ។

ក្នុងករណីខាងលើ អ្នកកាន់អាជ្ញាប័ណ្ណទឹកត្រូវធ្វើសេចក្តីបញ្ជាក់ជាលាយលក្ខណ៍អក្សរ មកក្រសួងធនធានទឹក និងឧតុនិយម ដើម្បីបំភ្លឺអំពីមូលហេតុនៃការប្រព្រឹត្តរបស់ខ្លួន ។ រាល់កំហុសឆ្គង អាចតម្រូវឱ្យអ្នកកាន់អាជ្ញាប័ណ្ណទឹកធ្វើការទូទាត់ជាសំណងក្នុងរយៈពេលមួយកំណត់ ។

**មាត្រា ១៨.-**

លើរាល់ការសម្រេចរបស់មន្ត្រីមានសមត្ថកិច្ចនៃក្រសួងធនធានទឹក និងឧតុនិយម អ្នកកាន់អាជ្ញាប័ណ្ណទឹកមានសិទ្ធិតវ៉ាទៅប្រធានស្ថាប័នក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលចេញសេចក្តីសម្រេចខាងលើនេះ ។ ពាក្យតវ៉ាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីមូលហេតុ ។

ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួង អ្នកកាន់អាជ្ញាប័ណ្ណទឹកអាចធ្វើបណ្តឹងទៅតុលាការតាមច្បាប់ ។

## ជំពូកទី ៤
## សហគមន៍កសិករប្រើប្រាស់ទឹក

**មាត្រា ១៩.-**

ដើម្បីធានាបាននូវការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ក្រសួងធនធានទឹក និងឧតុនិយមត្រូវទទួលខុសត្រូវលើការរៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។

កសិករដែលប្រើប្រាស់ទឹកក្នុងប្រព័ន្ធធារាសាស្ត្រជាមួយគ្នា ឬ ផ្នែកណាមួយនៃប្រព័ន្ធនេះ មានសិទ្ធិបង្កើតជាសហគមន៍កសិករប្រើប្រាស់ទឹក ។

លក្ខន្តិកៈនៃសហគមន៍កសិករប្រើប្រាស់ទឹកត្រូវចុះក្នុងបញ្ជីសហគមន៍កសិករប្រើប្រាស់ទឹកនៅមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្រុង ។ បន្ទាប់ពីការចុះបញ្ជីនេះ សហគមន៍កសិករប្រើប្រាស់ទឹក មានសិទ្ធិគ្រប់គ្រាន់ក្នុងការអនុវត្តន៍នូវលក្ខន្តិកៈរបស់ខ្លួននិងត្រូវបានទទួលស្គាល់ជាផ្លូវការ ។

នីតិវិធីនៃការបង្កើត ការរំលាយចោល តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ទឹកក្រោមដី

**មាត្រា ២០.-**

បុគ្គលដែលជីក ឬ ខួងអណ្តូងទឹកក្នុងគោលបំណងធ្វើជាមុខរបរ ឬ អាជីវកម្ម ត្រូវផ្តល់របាយការណ៍លំអិតស្តីពីដំណើរការ លក្ខណៈបច្ចេកទេស និងព័ត៌មានផ្សេងៗទៀតនៃការជីក ឬ ខួងអណ្តូងទឹករបស់ខ្លួនមកក្រសួងធនធានទឹក និងឧតុនិយម ។

ការប្រើប្រាស់ទឹកក្រោមដី និងល្អាងទឹកក្រោមដីក្នុងគោលបំណងធ្វើជាមុខរបរ ឬ ធ្វើអាជីវកម្មដែលលើសពីកំរិតដែលមានចែងក្នុងមាត្រា ១១ តម្រូវឱ្យមានការសុំអាជ្ញាប័ណ្ណទឹក ។

ការកំណត់តំបន់ហាមឃាត់ នឹងមានចែងក្នុងអនុក្រឹត្យ ។

**មាត្រា ២១.-**

បុគ្គលទាំងឡាយ ដែលបានជួបប្រទះប្រភពទឹកក្រោមដី ល្បាងទឹកក្រោមដី ក្នុងពេលបំពេញការងាររុករករ៉ែ និងសកម្មភាពផ្សេងៗទៀត ត្រូវផ្តល់ព័ត៌មានមកក្រសួងធនធានទឹក និងឧតុនិយម ។

## ជំពូកទី ៦
## ការការពារគុណភាពទឹក

**មាត្រា ២២.-**

រាល់ការបញ្ចេញចោល ការទុកចោល ឬ ការរក្សាទុកនូវសារធាតុពុលដែលអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ និង រុក្ខជាតិ ត្រូវតែសុំអាជ្ញាបណ្ណ័ទឹក ឬ ការអនុញ្ញាត ។

ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹកសំណល់នឹងមានកំណត់ដោយអនុក្រឹត្យ ។

រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា ។

**មាត្រា ២៣.-**

ក្រសួងធនធានទឹក និងឧតុនិយម អាចប្រកាសទុកជាតំបន់អាសន្ន ឬ ជាតំបន់ហាមឃាត់ការប្រើប្រាស់ទឹក ក្នុងករណីដែល :

-ទឹកលើដី ឬ ទឹកក្រោមដីត្រូវបានប៉ះពាល់ផ្នែកបរិមាណ គុណភាព ឬ គុណភាពអេកូឡូស៊ី

-ទឹកលើទីជម្រាលដែលកំពុងរងការគំរាមកំហែងដោយសកម្មភាពមនុស្ស ឬ ធម្មជាតិ

-ទឹកដែលបណ្តាលឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ។

ដែនភូមិសាស្ត្រនៃតំបន់អាសន្ន ឬ តំបន់ហាមឃាត់នោះ ត្រូវកំណត់តាមករណីនីមួយៗ ដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

## ជំពូកទី ៧
## ការការពារគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត

**មាត្រា ២៤.-**

ក្នុងការការពារគ្រោះទឹកជំនន់ ក្រសួងធនធានទឹក និងឧតុនិយមដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន អាចប្រកាសកំណត់តំបន់ទំនាបជាតំបន់ស្រូបយកទឹកជំនន់ ។

នៅក្នុងតំបន់ការពារគ្រោះទឹកជំនន់ ក្រសួងធនធានទឹក និងឧតុនិយមរួមជាមួយស្ថាប័ន និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ត្រូវរៀបចំផែនការស្តីពីវិធានការទប់ស្កាត់ និងត្រួតពិនិត្យគ្រោះទឹកជំនន់ ដើម្បីធានាសុវត្ថិភាពជីវិតមនុស្ស សត្វ និងទ្រព្យសម្បត្តិ ។

ក្រសួងធនធានទឹក និងឧតុនិយមអាចហាមឃាត់ជាបណ្តោះអាសន្ននូវសកម្មភាពនានាដែលបង្កការខូចខាតដល់វិធានការការពារគ្រោះទឹកជំនន់ ឬ ដែលរារាំងចរន្តទឹកហូរធម្មជាតិ ។

**មាត្រា ២៥.-**

ក្នុងករណីដែលពិនិត្យឃើញថា សំណង់ការងារទឹកទាំងឡាយដែលមិនមានស្ថិរភាពគ្រប់គ្រាន់ ឬ អាចនឹងបង្កឱ្យមានមហន្តរាយប៉ះពាល់ដល់សង្គមជាតិ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋានដើម្បីហាមឃាត់ជាបន្ទាន់ទៅតាមសមត្ថកិច្ចរៀងៗខ្លួន ។

**មាត្រា ២៦.-**

នៅពេលមានគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ក្រសួងធនធានទឹក និងឧតុនិយមជាសេនាធិការផ្ទាល់ឱ្យរាជរដ្ឋាភិបាលក្នុងការចាត់ចែងការងារ ដោយរួមសហការជាមួយក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

4

3/13

## ជំពូកទី ៨
## សេវភាព

**មាត្រា ២៧.-**

កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីផ្នែកខាងលើអាចត្រងទឹកទុក ប្រើប្រាស់ទឹកភ្លៀង និងទឹកហូរកាត់លើដីកម្មសិទ្ធិសម្រាប់គោលបំណងដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ដោយមិនឱ្យប៉ះពាល់ដល់ផលប្រយោជន៍អ្នកប្រើប្រាស់ទឹកផ្នែកខាងក្រោម ។

កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីផ្នែកខាងក្រោមអាចទទួលត្រងទឹកទុក និងប្រើប្រាស់បាននូវបរិមាណទឹកធម្មជាតិដែលហូរពីដីផ្នែកខាងលើ ក៏ប៉ុន្តែបុគ្គលទាំងនេះគ្មានសិទ្ធិរាំងចរន្តទឹកដោយសារការសាងសង់ថ្នល់ ទំនប់តូច ធំ ឬ សំណង់ផ្សេងៗទៀតដែលអាចរក្សាទឹកទុកបានឡើយ លើកលែងតែមានការអនុញ្ញាត ។

ការខូចខាតណាមួយបណ្តាលមកពីកម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីដែលបានរំលោភទៅនឹងបទប្បញ្ញត្តិនៃមាត្រានេះ ត្រូវចេញសងនូវការខូចខាតនោះ ។

**មាត្រា ២៨.-**

កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីកសិកម្ម ត្រូវអនុញ្ញាតឱ្យចរន្តទឹកហូរកាត់លើដីរបស់ខ្លួនតាមលំនាំធម្មជាតិទៅកាន់ដីអ្នកជិតខាង ដើម្បីបំពេញនូវតម្រូវការស្រោចស្រពលើដីកសិកម្ម ឬ តម្រូវការផ្សេងៗទៀត ។

**មាត្រា ២៩.-**

សេវភាពបម្រើប្រយោជន៍សាធារណៈ គឺជាបទប្បញ្ញត្តិពិសេសដែលតម្រូវឱ្យកម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីប្រតិបត្តិតាម ។

អ្នករៀបចំសេវភាពប្រព័ន្ធនាំទឹកឆ្លងកាត់លើដីអ្នកជិតខាងតាមវិធីនាំទឹកលើដី ឬ ក្រោមដីមិនត្រូវធ្វើឱ្យខូចខាតផលប្រយោជន៍របស់អ្នកដទៃ ឯការបញ្ចេញទឹកចោល ទឹកសំណល់ ទឹកភ្លៀង និងការដោះទឹក ក៏ស្ថិតនៅក្នុងក្របខ័ណ្ឌសេវភាពដែរ ។

ក្នុងករណីមានការខូចខាត អ្នកទទួលផលប្រយោជន៍ពីសេវភាពដូចមានចែងក្នុងមាត្រានេះ ត្រូវទទួលខុសត្រូវសងការខូចខាតដល់កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដីដែលជាអ្នករងគ្រោះ ។

**មាត្រា ៣០.-**

ម្ចាស់ដីជិតខាងគ្នាមានសិទ្ធិប្រើប្រាស់សំណង់ដែលមានចែងក្នុងមាត្រា ២៩ នៃច្បាប់នេះ ។

ក្នុងករណីនេះ កម្មសិទ្ធិករត្រូវចូលរួមចំណែកតាមសមាមាត្រនៃការប្រើប្រាស់សំណង់ តម្លៃនៃការសាងសង់ កិច្ចដំណើរការ ការថែទាំសំណង់ និងការចំណាយលើការកែប្រែនានាដែលចាំបាច់ ។

**មាត្រា ៣១.-**

សេវភាពនៃច្បាប់នេះ អស់សុពលភាពស្របតាមបញ្ញត្តិច្បាប់ភូមិបាលស្តីពីសេវភាព ។

**មាត្រា ៣២.-**

រាល់វិវាទដែលពាក់ពន្ធ័ការបង្កើត និងដំណើរការសេវភាពក្នុងការប្រើប្រាស់ទឹកត្រូវសម្រួលដោះស្រាយដោយក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

**មាត្រា ៣៣.-**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងធនធានទឹក និងឧតុនិយមដែលធ្វើការតាមដានត្រួតពិនិត្យបច្ចេកទេសពាក់ព័ន្ធនឹងការប្រើប្រាស់ទឹក អាចចូលទៅក្នុងដីកម្មសិទ្ធបានដោយគ្រាន់តែធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខណ៍អក្សរជាមុនទៅដល់កម្មសិទ្ធិករ ឬ អ្នកកាន់កាប់ដី ។

ក្នុងវេលាបំពេញបេសកកម្ម មន្ត្រីមានសមត្ថកិច្ចត្រូវមានលិខិតបេសកកម្មរបស់ខ្លួន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ·

## ជំពូកទី ៩

## ទន្លេអន្តរជាតិ

**មាត្រា ៣៤.-**

ព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិ និងកាតព្វកិច្ចចាត់ចែងចំណែកសមស្រប និងដោយស្មើភាពក្នុងការប្រើប្រាស់ ការអភិវឌ្ឍន៍ និងការគ្រប់គ្រងទន្លេអន្តរជាតិក្នុងទឹកដីរបស់ខ្លួនស្របតាមសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ដែលមានព្រះរាជាណាចក្រកម្ពុជាជាភាគី ។

ក្រសួងធនធានទឹក និងឧតុនិយមយកចិត្តទុកដាក់ឱ្យមានការប្រើប្រាស់ទឹកអាងទន្លេមេគង្គលើគ្រប់វិស័យ ដោយរួមទាំងវិស័យដឹកជញ្ជូនផងឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពស្របតាមគោលការណ៍របស់គណៈកម្មាធិការជាតិទន្លេមេគង្គ ។

## ជំពូកទី ១០

## រង្វាន់លើកទឹកចិត្ត និងទោសប្បញ្ញត្តិ

**មាត្រា ៣៥.-**

រាជរដ្ឋាភិបាលអាចផ្តល់រង្វាន់លើកទឹកចិត្ត ឬ ភាពអនុគ្រោះផ្សេងៗដល់បុគ្គលទាំងឡាយដែលបានចូលរួមក្នុងការសិក្សាស្រាវជ្រាវ ការបង្កើតបច្ចេកវិទ្យាថ្មីៗ ឬ ការដំឡើងឧបករណ៍ទំនើបដែលជួយកាត់បន្ថយកាកសំណល់ និងជួយបង្កើនគុណភាពទឹកដើម្បីឱ្យការប្រើប្រាស់ទឹកមានប្រសិទ្ធភាពខ្ពស់ ។

លក្ខណៈវិនិច្ឆ័យ និងបែបបទសម្រាប់ការផ្តល់រង្វាន់លើកទឹកចិត្ត ឬ ភាពអនុគ្រោះផ្សេងៗត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា ៣៦.-**

បទល្មើសនឹងបញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :

១-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីពីររយពាន់ (២០០.០០០)រៀល ដល់ពីរលាន (២.០០០.០០០) រៀល ចំពោះបុគ្គលណាដែល :

-រំលោភលើលក្ខខណ្ឌនានាដែលមានកំណត់ក្នុងអាជ្ញាប័ណ្ណទឹក ។

ROYAUME DU CAMBODGE * LE MINISTERE DU PALAIS ROYAL *

6/18

-រារាំងដោយគ្មានមូលហេតុត្រឹមត្រូវ មិនឱ្យមន្ត្រីមានសមត្ថកិច្ចបំពេញនូវតួនាទីរបស់ខ្លួន ។

-សង់សំណង់ធារាសាស្ត្រដោយគ្មានអាជ្ញាប័ណ្ណទឹក ។

២-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីពីរលាន (២.០០០.០០០)រៀល ដល់ប្រាំលាន(៥.០០០.០០០)រៀល និង ឬ ដាក់ពន្ធនាគារពីមួយ(១)ខែ ដល់ប្រាំមួយ(៦)ខែ ចំពោះបុគ្គលណាដែល :

-ប្រើប្រាស់ទឹកដោយគ្មានសុំអាជ្ញាប័ណ្ណទឹក ឬ លិខិតអនុញ្ញាត ក្នុងករណីដែលច្បាប់តម្រូវឱ្យមាន ។

-ជីក ឬ ខួងអណ្តូងយកទឹកក្រោមដីធ្វើអាជីវកម្ម ដោយគ្មានអាជ្ញាប័ណ្ណទឹក ។ ប្រាក់ពិន័យនេះនឹងឡើងទ្វេដង កាលណាការជីក ឬខួងអណ្តូងបណ្តាលឱ្យមានការស្រុត ឬបាក់ដី ។ ជនល្មើសត្រូវទទួលខុសត្រូវចំពោះការខូចខាត ដែលបណ្តាលមកពីការស្រុត ឬបាក់ដីនេះ ។

៣-ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០)រៀល និង ឬ ដាក់ពន្ធនាគារពីមួយ(១)ឆ្នាំ ដល់ប្រាំ(៥)ឆ្នាំ ចំពោះបុគ្គលណាដែល :

-លុបបឹងធម្មជាតិ ស្រះ ត្រពាំង និងអាងទឹកដោយគ្មានលិខិតអនុញ្ញាត ។

-បង្ហូរចោលទឹកសំណល់ដែលមានជាតិពុលចូលក្នុងប្រភពទឹកដោយគ្មានអាជ្ញាប័ណ្ណទឹក ។

-ធ្វើសកម្មភាពបំពាននៅក្នុងតំបន់ហាមឃាត់ ។

-បង្កឧបសគ្គ ឬ ធ្វើឱ្យរាំងស្ទះដល់លំហូរធម្មជាតិនៃទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយដោយគ្មានការអនុញ្ញាត ។

-ធ្វើអាជីវកម្មខ្សាច់ ដី ថ្ម និងក្រួសពីបាតទន្លេ ស្ទឹង ព្រែក និងច្រាំងដោយគ្មានអាជ្ញាប័ណ្ណទឹក ។

៤-គ្រប់ករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេមួយជាពីរ ។

**មាត្រា ៣៧.-**

បុគ្គលណាដែលបង្កឱ្យមានការខូចខាតដល់សំណង់ការងារទឹកសាធារណៈ នឹងត្រូវទទួលការផ្តន្ទាទោសទៅតាមក្រមព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៣៨.-**

បន្ថែមលើទោសប្បញ្ញត្តិដូចមានចែងក្នុងមាត្រាខាងលើ ជនល្មើសត្រូវរុះរើចេញនូវប្រភេទសំណង់ ដែលខ្លួនបានសាងសង់ និងរៀបចំជួសជុលទីកន្លែងឱ្យបានដូចស្ថានភាពដើមវិញ ហើយឧបករណ៍ គ្រឿងចក្រដែលពាក់ព័ន្ធនឹងបទល្មើស ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៣៩.-**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងធនធានទឹក និងឧតុនិយមដែលបានសមគំនិតជាមួយជនល្មើស ឬ ជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើស ត្រូវទទួលទោសចំពោះមុខច្បាប់ ។

## ជំពូកទី ១១
## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤១.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*ពកម.០៧០៦.២៧៣*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

**ហត្ថលេខា**

**លឹម គានហោ**

លេខ ២៣៦ ជ.ល
ឆ្នាំ២០០៧

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៧១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី៤ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីសម្រេចលេខ ៤៧៦ រស. ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០០៦ ស្តីពីរបបប្រាក់បំណាច់ របបធានារ៉ាប់រងសង្គម និងរបបបេសកកម្មរបស់តំណាងរាស្ត្រ
- បានទ្រង់យល់សេចក្តីសម្រេចរួមលេខ ០១ ពរក. ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ស្ថាប័ននីតិបញ្ញត្តិ ស្តីពី បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ
- បានទ្រង់យល់សេចក្តីស្នើរបស់ សម្តេចប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **សាន ចាន់យ៉ាដា** ជាជំនួយការលោកជំទាវ **ឃួន សុដារី** ប្រធានគណៈកម្មការ សិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និង ទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា មានឋានៈស្មើអគ្គនាយក ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**

**នរោត្តម សីហមុនី**

ពល.០៧០៧.២៨៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៧*

លេខ ៤៩៦ ព.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ម៉ែន ជាតេ

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧០៧.២៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៧

លេខ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០០៧
អគ្គលេខាធិការរដ្ឋាភិបាល
ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម ផាំ ថេយឿត

នូវ

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ពរល.០៧០៧.២៩០ នរោត្តម សីហមុនី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៧*

លេខ ២៨៤ ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ប៊ុន ឈិនកេង

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានប្រគល់ឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** នាយអាវុធហត្ថ ជូន

- លោក **ខូច សម្បត្តិ** អត្តលេខ ០០៤៣២២

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*៣៧.០៧០៧.២៩៦*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៧*

លេខ:២០៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៧៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា ព្រះមហាក្សត្រ ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតម្លើងឋានន្តរស័ក្តិ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

**ក_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ឯក**

១-ឧត្តមសេនីយ៍ទោ តេង ឈុន អត្តលេខ ០០០៣១៧

២-ឧត្តមសេនីយ៍ទោ ឈិន ចាន់ពណ៌ អត្តលេខ ០០១១៣៥

៣-ឧត្តមសេនីយ៍ទោ ខន ពិសេន អត្តលេខ ០០០៣៥៧

៤-ឧត្តមសេនីយ៍ទោ ជ័យ សុន អត្តលេខ ០០០៧៦១

**ខ_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមនាវីឯក**

១-ឧត្តមនាវីទោ មាស ចំ អត្តលេខ ០០០០៩៤

២-ឧត្តមនាវីទោ ទៀ ចិញ អត្តលេខ ០០០១៧១

**គ_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ**

១-ឧត្តមសេនីយ៍ត្រី ទៀង សារ៉ាន អត្តលេខ ០០១៤០៣

២-ឧត្តមសេនីយ៍ត្រី មាស លី អត្តលេខ ០០០៥៣៨
៣-ឧត្តមសេនីយ៍ត្រី ខិម ទិចិត្រ អត្តលេខ ០០០៥៦៨
៤-ឧត្តមសេនីយ៍ត្រី ម៉ុល និត្យ អត្តលេខ ០០០៤៥៣
៥-ឧត្តមសេនីយ៍ត្រី គីម ផាន់ណា អត្តលេខ ០០០៧២២
៦-ឧត្តមសេនីយ៍ត្រី ព្រហ្ម ផេង អត្តលេខ ០០០៤២៨
៧-ឧត្តមសេនីយ៍ត្រី យឿង សុខុន អត្តលេខ ០០០១២៣
៨-ឧត្តមសេនីយ៍ត្រី ស្រី អឹក អត្តលេខ ០០០០៥៧

**ឃ_តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក ចេន សារឿន អត្តលេខ ០០០៧០៨
២-វរសេនីយ៍ឯក ជ័យ រ៉ា អត្តលេខ ០០១៦៣១
៣-វរសេនីយ៍ឯក គង ឈុន អត្តលេខ ០០៤២៥៨
៤-វរសេនីយ៍ឯក ម៉ម សំ អត្តលេខ ០០២៥១២
៥-វរសេនីយ៍ឯក អ៊ុង បូរ៉ាមី អត្តលេខ ០១៩៥៦៤
៦-វរសេនីយ៍ឯក និត្យ ចំនួមបូណ៌មី អត្តលេខ ០០៨៣៥៨
៧-វរសេនីយ៍ឯក លី សុខមើង អត្តលេខ ០២១៧៦១
៨-វរសេនីយ៍ឯក ម៉ៅ ចន្ទ្ធារី អត្តលេខ ០០២៥២០
៩-វរសេនីយ៍ឯក អ៊ុំ ចន្ទី អត្តលេខ ០០២២០៨
១០-វរសេនីយ៍ឯក ជា សារិន អត្តលេខ ០០១១២៧

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

**នរោត្តម សីហមុនី**

នស/រកត.០៧០៧.២៩២

លេខៈ ២០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៧

ស៊ុន ជិនគេង

# ព្រះរាជក្រឹត្យ

នស/រកត/០៧០៧/២៧៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកស្រី ចា ចន្ធី

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៧.២៨៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៧

លេខ ៧៧៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស / រកត / ០៧០៧ / ២៧៨

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទិ ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងលោកជំទាវ ម៉ែន នារីសោភ័គ ជានាយិការងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧៧.០៧០៧.២៩៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៧

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០០៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៨ អនក្រ.បក

## <u>អនុក្រឹត្យ</u>

## ស្តីពី

## ការធ្វើអនុបយោគទីតាំងកោះមួយចំនួន ក្នុងភូមិសាស្ត្រ ក្រុងព្រះសីហនុ និងខេត្តកំពត ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៅ "ក.អ.ក" នាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៧
- យោងតាមតម្រូវការចាំបាច់នៃការអភិវឌ្ឍន៍វិស័យទេសចរណ៍

## <u>សម្រេច</u>

**<u>មាត្រា១</u>:** ត្រូវបានធ្វើអនុបយោគទីតាំងកោះមួយចំនួន ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីបំរើការងារអភិវឌ្ឍន៍វិញ ដូចខាងក្រោម :

១- កោះសេះ ស្ថិតក្នុងភូមិសាស្ត្រ ខេត្តកំពត ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី$103^0$47'05"E ដល់ $103^0$49'28" និងចន្លោះខ្សែរយៈទទឹង(ជើង) ទី$10^0$24'11"N ដល់ $10^0$26'19" ទំហំសរុប ៧៥៨.២ហិកតា។

២- កោះតាកៀវ ស្ថិតក្នុងភូមិសាស្ត្រ ក្រុងព្រះសីហនុ ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី $103^0$34'41" ដល់ $103^0$36'30" និងចន្លោះខ្សែរយៈទទឹង(ជើង)ទី $10^0$28'28" ដល់ $10^0$30'37"ទំហំសរុប ៧១៥.៣០ម២។

៣- កោះថាស(កោងកាង) ស្ថិតក្នុងភូមិសាស្ត្រ ក្រុងព្រះសីហនុ ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី$103^0$24'31" ដល់ $103^0$25'57" និងចន្លោះខ្សែរយៈទទឹង(ជើង) ទី$10^0$36'17" ដល់ $10^0$36' 43" ទំហំសរុប១០២ហិកតា។

៤- កោះបង ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់កោះរុង ក្រុងព្រះសីហនុ ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី$103^0$15'46" ដល់ $103^0$15'54" និងចន្លោះខ្សែរយៈទទឹង(ជើង) ទី$10^0$45'29" ដល់ $10^0$45'36" ទំហំសរុប ៤.២៤ហិកតា។

៥- កោះអូន ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់កោះរុង ក្រុងព្រះសីហនុ ចន្លោះខ្សែរយៈបណ្តោយ(កើត) ទី$103^0$15'41" ដល់ $103^0$15'47" និងចន្លោះខ្សែរយៈទទឹង(ជើង)ទី$10^0$45'18" ដល់ $10^0$45'27" ទំហំសរុប ៣.១៨ហិកតា។

៦- កោះដែកគោល ស្ថិតក្នុងភូមិសាស្ត្រ សង្កាត់លេខ៣ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣:** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ អភិបាលក្រុងព្រះសីហនុ អភិបាលខេត្តកំពត អភិបាលគ្រប់ខេត្ត-ក្រុង និងប្រធានអង្គភាព ទាំងអស់ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣ ដើម្បីអនុវត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃ ទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/១២០២/០២០. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ១២០៦/០៣៥. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក. ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧១ អនក្រ.បក. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១ :** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៦១៥ លានរៀល ( ប្រាំមួយរយដប់ប្រាំលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦៥( ឧបត្ថម្ភកធន និង ជំនួយសង្គម ) ជូនក្រសួងសុខាភិបាលសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧។

**មាត្រា២ :** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ឧបត្ថម្ភជូនមជ្ឈមណ្ឌលបេះដូង ដើម្បីដំណើរការងារក្នុងឆ្នាំ ២០០៧ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧

សែន

**បានយកសេចក្ដីជំរាបជូន**

**សម្ដេចនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥០៨ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីគ្រប់គ្រងអប់រំ និងបុគ្គលិកសិក្សា ក្រោមឱវាទមន្ទីរអប់រំ យុវជន និងកីឡា ខេត្តក្រចេះ ចំនួន ២៣៩ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចរយៈពេលកន្លងមក ដូចមានរាយនាមខាងក្រោម :-

**ក.មេដាយមាសការងារ :**

| | | | | | |
|---|---|---|---|---|---|
| ១ | លោក ប៊ុន | ជេង | ប្រធានការិយាល័យ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ក្រចេះ |
| ២ | លោក ហេង | ឡេង | ប្រធាន | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ឆ្លូង |
| ៣ | លោក ទិង | មុនី | នាយក | សាលាបឋមសិក្សាព្រែកសំរោង | ឆ្លូង |
| ៤ | លោក ទាម | គីមឆេង | នាយក | អនុវិទ្យាល័យកញ្ជរ | ឆ្លូង |
| ៥ | លោក ឈឹម | វណ្ណា | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ឆ្លូង |
| ៦ | លោក ឈុន | ឆាន | គ្រូបង្រៀន | សាលាបឋមសិក្សាព្រៃគោ | ឆ្លូង |
| ៧ | លោក រស់ | ស៊ីនិត | គ្រូបង្រៀន | អនុវិទ្យាល័យមុនីកេសរ | ឆ្លូង |
| ៨ | លោកស្រី មុត | ណារី | គ្រូបង្រៀន | សាលាបឋមសិក្សាភូមិកណ្តាល | ឆ្លូង |
| ៩ | លោកស្រី ទុំ | ផល្លី | គ្រូបង្រៀន | សាលាបឋមសិក្សាព្រែកចំឡាក់ | ឆ្លូង |
| ១០ | លោកស្រី លឹម | គីមហ៊ាង | គ្រូបង្រៀន | សាលាបឋមសិក្សាហាន់ជ័យ | ឆ្លូង |
| ១១ | លោកស្រី ហែម | ស៊ីរី | គ្រូបង្រៀន | សាលាបឋមសិក្សាពង្រ ៣ | ឆ្លូង |
| ១២ | លោក ហោ | សុទ្ធ | ប្រធាន | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ក្រចេះ |

| | | | | | |
|---|---|---|---|---|---|
| ១៣ | លោក ទិវ | វុទ្ធី | នាយក | សាលាបឋមសិក្សាសំបុក | ក្រចេះ |
| ១៤ | លោក នី | ម៉ែត | នាយក | សាលាបឋមសិក្សា ២៤ កញ្ញា | ក្រចេះ |
| ១៥ | លោក អ៊ុក | សឿន | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ក្រចេះ |
| ១៦ | លោកស្រី ឈិត | សារឹម | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ក្រចេះ |
| ១៧ | លោក ជិន | ប៊ុណ្ណារ៉ុង | មន្ត្រី | វិទ្យាល័យព្រះកុសុមៈ | ក្រចេះ |
| ១៨ | លោក ឌី | ម៉េង | មន្ត្រី | សាលាបឋមសិក្សាអញ្ចាញ | ក្រចេះ |
| ១៩ | លោក ស៊ី | អាង | មន្ត្រី | អនុវិទ្យាល័យកោះស្រែង | ក្រចេះ |
| ២០ | លោកស្រី ខេង | ឆៃ | បណ្ណារក្ស | សាលាបឋមសិក្សា ២៤ កញ្ញា | ក្រចេះ |
| ២១ | លោក ម៉ក់ | ស៊្រុន | គ្រូបង្រៀន | សាលាបឋមសិក្សាម្រើម | ក្រចេះ |
| ២២ | លោក ហោ | សុទ្ធារិទ្ធ | គ្រូបង្រៀន | សាលាបឋមសិក្សាអាលច | ក្រចេះ |
| ២៣ | លោក ណោ | ហឿង | គ្រូបង្រៀន | សាលាបឋមសិក្សាបុសលាវ | ក្រចេះ |
| ២៤ | លោកស្រី យូ | ឆេង | គ្រូបង្រៀន | សាលាបឋមសិក្សាជ្រូវក្រូច | ក្រចេះ |
| ២៥ | លោក យឹន | យាន | គ្រូបង្រៀន | សាលាបឋមសិក្សាគោលាប់ | ក្រចេះ |
| ២៦ | លោក អ៊ី | ណារ៉ា | គ្រូបង្រៀន | សាលាបឋមសិក្សាអនុវត្ត | ក្រចេះ |
| ២៧ | លោក ឥម | សូភ័ន់ | គ្រូបង្រៀន | សាលាបឋមសិក្សាសំបុក | ក្រចេះ |
| ២៨ | លោក សឿ | ឡូញ | អនុប្រធាន | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ព្រែកប្រសព្វ |
| ២៩ | លោក មិត | សុភអេង | នាយក | វិទ្យាល័យចំបក់ | ព្រែកប្រសព្វ |
| ៣០ | លោក ប៊ុន | សុខលាង | នាយក | សាលាបឋមសិក្សាឬស្សីកែវ | ព្រែកប្រសព្វ |
| ៣១ | លោកស្រី ជ | ស៊ីមុយ | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ព្រែកប្រសព្វ |
| ៣២ | លោក យូ | សំអ៊ិត | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ព្រែកប្រសព្វ |
| ៣៣ | លោក ប៉ុល | ទ្រី | មន្ត្រី | វិទ្យាល័យចំបក់ | ព្រែកប្រសព្វ |
| ៣៤ | លោកស្រី អ៊ារ | ចាន់ឌី | មន្ត្រី | សាលាបឋមសិក្សាឬស្សីកែវ | ព្រែកប្រសព្វ |
| ៣៥ | លោក គីម | អេងឡុង | គ្រូបង្រៀន | វិទ្យាល័យចំបក់ | ព្រែកប្រសព្វ |
| ៣៦ | លោក យី | វុទ្ធា | គ្រូបង្រៀន | វិទ្យាល័យចំបក់ | ព្រែកប្រសព្វ |
| ៣៧ | លោកស្រី គី | សុខឡេង | គ្រូបង្រៀន | វិទ្យាល័យព្រែកប្រសព្វ | ព្រែកប្រសព្វ |
| ៣៨ | លោកស្រី អ៊ុក | លាងទូច | គ្រូបង្រៀន | សាលាបឋមសិក្សាព្រះគ្រូគីមឯម | ព្រែកប្រសព្វ |
| ៣៩ | លោកស្រី ហេង | ចាន់ណា | គ្រូបង្រៀន | សាលាបឋមសិក្សាបឹងរៃ | ព្រែកប្រសព្វ |
| ៤០ | លោក ម៉ម | ស្ដើង | គ្រូបង្រៀន | សាលាបឋមសិក្សាវត្តចំបក់ | ព្រែកប្រសព្វ |
| ៤១ | លោកស្រី ស៊ី | គីមលូ | អនុប្រធាន | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | សំបូរ |
| ៤២ | លោក ទូន | ផល្លា | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | សំបូរ |
| ៤៣ | លោក អ៊ឹង | ណារ៉ុងដែន | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | សំបូរ |
| ៤៤ | លោក ញ៉ឹក | ស្រាប | គ្រូបង្រៀន | សាលាបឋមសិក្សាសំបូរ | សំបូរ |
| ៤៥ | លោកស្រី ហ៊ិន | ចាន់ណារី | គ្រូបង្រៀន | សាលាបឋមសិក្សាសណ្ដាន់ ២ | សំបូរ |
| ៤៦ | លោក ណាស់ | ឈុនសេង | គ្រូបង្រៀន | សាលាបឋមសិក្សាក្រៀង | សំបូរ |

| | | | | | |
|---|---|---|---|---|---|
| ៤៧ | លោក កង | សំអាត | នាយក | សាលាបឋមសិក្សាតាពុំ | ស្ទួល |
| ៤៨ | លោក ប៊ុន | ទៀប | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ស្ទួល |
| ៤៩ | លោកស្រី ស៊ីន | សុចាន់ដារី | គ្រូបង្រៀន | សាលាបឋមសិក្សាព្រែកក្តី | ស្ទួល |
| ៥០ | លោក ហេង | ផល | គ្រូបង្រៀន | សាលាបឋមសិក្សាប្រភិញ | ស្ទួល |

**ខ.មេដាយផ្ទាក់ការងារ :**

| | | | | | |
|---|---|---|---|---|---|
| ១ | លោក ឡាយ | បូរ៉ា | នាយក | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត | ក្រចេះ |
| ២ | លោក មាស | វីរតន៍ | មន្ត្រី | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ក្រចេះ |
| ៣ | លោក ប៉ក់ | ទឹម | មន្ត្រី | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ក្រចេះ |
| ៤ | លោកស្រី ទាម | សូខាំហ៊ីន | គ្រូបង្រៀន | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត | ក្រចេះ |
| ៥ | លោក សូ | មករា | នាយក | សាលាបឋមសិក្សាព្រៃគោ | ឆ្លូង |
| ៦ | លោកស្រី យិន | សូម៉ា | នាយិកា | វិទ្យាល័យតាត ឈន់ | ឆ្លូង |
| ៧ | លោកស្រី អ៊ាប | ណៃសឿន | នាយិកា | សាលាបឋមសិក្សាពង្រ ៣ | ឆ្លូង |
| ៨ | លោក អន | សិទ្ធី | គ្រូបង្រៀន | សាលាបឋមសិក្សាភូមិកណ្តាល | ឆ្លូង |
| ៩ | លោក លឹម | វុទ្ធី | គ្រូបង្រៀន | សាលាបឋមសិក្សាហាន់ជ័យលើ | ឆ្លូង |
| ១០ | លោក យឹម | ចាន់ថា | គ្រូបង្រៀន | សាលាបឋមសិក្សាពង្រ ៣ | ឆ្លូង |
| ១១ | លោកស្រី ហេ | សុខម៉េង | គ្រូបង្រៀន | អនុវិទ្យាល័យមុនីកេសរ | ឆ្លូង |
| ១២ | លោក ឈាន | វិចិត្រ | គ្រូបង្រៀន | អនុវិទ្យាល័យខ្សាច់អណ្តែត | ឆ្លូង |
| ១៣ | លោកស្រី ច័ន្ទ | សូរិយា | គ្រូបង្រៀន | សាលាបឋមសិក្សាកញ្ជរ | ឆ្លូង |
| ១៤ | លោកស្រី គិន | គីមចូត | គ្រូបង្រៀន | សាលាបឋមសិក្សាព្រែកសំរោង | ឆ្លូង |
| ១៥ | លោកស្រី ម៉ម | ដាឡាត់ | គ្រូបង្រៀន | សាលាបឋមសិក្សាឈើទាលភ្លោះ | ឆ្លូង |
| ១៦ | លោកស្រី មាន | ចន្ទូ | គ្រូបង្រៀន | សាលាបឋមសិក្សាព្រៃគោ | ឆ្លូង |
| ១៧ | លោកស្រី គិវ | ស៊ីណា | គ្រូបង្រៀន | សាលាបឋមសិក្សាឆ្លូង | ឆ្លូង |
| ១៨ | លោក ហ៊ុយ | សាវី | គ្រូបង្រៀន | សាលាបឋមសិក្សាព្រែកសាម៉ាន់ | ឆ្លូង |
| ១៩ | លោក ជុត | ប៉េងស្រ៊ន | នាយក | សាលាបឋមសិក្សាក្រចេះក្រុង | ក្រចេះ |
| ២០ | លោកស្រី លឹម | ពៅ | នាយិកា | សាលាបឋមសិក្សាអនុវត្ត | ក្រចេះ |
| ២១ | លោក ឈុំ | ឆ្លួយ | នាយក | សាលាបឋមសិក្សាគាលាប់ | ក្រចេះ |
| ២២ | លោក ឌឹម | ប៊ុនធឿន | នាយក | សាលាបឋមសិក្សាក្រគរ | ក្រចេះ |
| ២៣ | លោក ទូ | ផល្លុន | នាយករង | អនុវិទ្យាល័យក្រចេះក្រុង | ក្រចេះ |
| ២៤ | លោក សំ | បួយ | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ក្រចេះ |
| ២៥ | លោកស្រី ឌី | គីមថាត | មន្ត្រី | ការិយាល័យអប់រំ យុវជន និងកីឡាស្រុក | ក្រចេះ |
| ២៦ | លោកស្រី ហេង | យូហួ | មន្ត្រី | សាលាបឋមសិក្សា២៤កញ្ញា | ក្រចេះ |
| ២៧ | លោក អ៊ាន | ប្រណិត | មន្ត្រី | អនុវិទ្យាល័យក្រចេះក្រុង | ក្រចេះ |
| ២៨ | លោកស្រី ទេព | សីហា | មន្ត្រី | សាលាបឋមសិក្សាក្រគរ | ក្រចេះ |
| ២៩ | លោក អ៊ូ | ឈាងលី | មន្ត្រី | សាលាបឋមសិក្សាសំបុក | ក្រចេះ |

| | | | | | |
|---|---|---|---|---|---|
| ៣០ | លោកស្រី កង | សុផល | គ្រូបង្រៀន | សាលាបឋមសិក្សា២៤កញ្ញា | ក្រចេះ |
| ៣១ | លោក ស៊ូ | សំអុល | គ្រូបង្រៀន | សាលាបឋមសិក្សាខ្លងពស់ | ក្រចេះ |
| ៣២ | លោក ខឹម | សាប៊ុត | គ្រូបង្រៀន | សាលាបឋមសិក្សាភូមិវត្ត | ក្រចេះ |
| ៣៣ | លោក ចាវ | ខ្នាន | គ្រូបង្រៀន | សាលាបឋមសិក្សាដំណាក់សសរ | ក្រចេះ |
